រាជធានីភ្នំពេញ ,ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤

# អនុក្រឹត្យលេខ ៧៨ អនក្រ
# ស្តីពីការបញ្ឈប់សកម្មភាពធ្វើអាជីវកម្មព្រៃគុបទូទាំងប្រទេស និងផ្អាកការដេញថ្លៃព្រៃគុបជាបណ្តោះអាសន្ន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ-ច្បាប់ លេខ ៣៥ ក្រច ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សំរេច

**មាត្រា ១ :** បញ្ឈប់សកម្មភាពធ្វើអាជីវកម្មព្រៃគុប នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៥ និង ផ្អាកការដេញថ្លៃព្រៃគុបជាបណ្តោះអាសន្ន ចាប់ពីឆ្នាំ ១៩៩៥ តទៅលើកលែងតែព្រៃគុបអុស និង កូនឈើសំរាប់ការប្រើប្រាស់របស់ប្រជារាស្ត្រ ។

**មាត្រា ២ :** បទបញ្ញត្តិ និង ច្បាប់អនុញ្ញាតទាំងឡាយណា ដែលបានចេញអោយពីមុនមកត្រូវចាត់ទុកជា និរាករណ៍ និង ជាមោឃៈ ។

**មាត្រា ៣ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្ត ក្រុង ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |